[១០៣] វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ៣ ពឹងផ្អែកនឹងអហេតុកវិបាកក្ខន្ធ១។ ធម៌មានវិបាកជាបកតី ពឹងផ្អែកនឹងធម៌មានវិបាកជាបកតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាបកតី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាបកតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ (ខន្ធ៣) ពឹងផ្អែកនឹងអហេតុកក្ខន្ធ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាបកតី។ វិបាកធម៌ ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាបកតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ។បេ។ ធម៌មានវិបាកជាបកតី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាបកតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាបកតីក្តី ពឹងផ្អែកនឹងធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាបកតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអហេតុកវិបាកក្ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ...។ វិបាកធម៌ ពឹងផ្អែកនឹងវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាបកតីផង ទើបកើតឡើង... ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាបកតី ទើបកើតឡើង... វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាបកតីក្តី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ។ ធម៌មានវិបាកជាបកតី ពឹងផ្អែកនឹងធម៌មានវិបាកជាបកតីផង

ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាបកតិផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈផង វត្ថុផង។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាបកតិ ពឹងផ្អែកនឹងវិបាកធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ។ សេចក្ដីបំប្រួញ។ បទទាំងអស់ បណ្ឌិតគប្បីឲ្យពិស្ដារចុះ។

[១០៤] ក្នុងនហេតុប្បច្ច័យ មានវារៈ១២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ១៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៥ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ១២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ១៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ១៧ ក្នុងនកម្មប្បច្ច័យ មានវារៈ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១ ក្នុងនឈានប្បច្ច័យ មានវារៈ៤ ក្នុងនមគ្គប្បច្ច័យ មានវារៈ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៥ ក្នុងនោវិគតប្បច្ច័យ មានវារៈ៥។

[១០៥] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះនហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ១២។ សេចក្ដីបំប្រួញ។ ... ក្នុងនោវិគតប្បច្ច័យ មានវារៈ៣។ បណ្ឌិតគប្បីរាប់ ដូចជាការរាប់នូវបច្ចនីយៈ ក្នុងកុសលត្តិកៈដែរ។

ចប់ បច្ចនីយៈ។

[១០៦] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៥ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ១៧។ សេចក្ដីបំប្រួញ។ ក្នុងនោវិគតប្បច្ច័យ មានវារៈ៥។ បណ្ឌិតគប្បីរាប់ ដូចជាការរាប់នូវអនុលោមបច្ចនីយៈ ក្នុងកុសលត្តិកដែរ។

ចប់ អនុលោមបច្ចនីយៈ។

[១០៧] ក្នុងអារម្មណប្បច្ច័យ មានវារៈ៧ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៧។បេ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ១២។ ក្នុងសហជាតប្បច្ច័យ មានវារៈ៣ ព្រោះនហេតុប្បច្ច័យ ព្រោះនអារម្មណប្បច្ច័យ ... ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ២។ សេចក្តីបំប្រួញ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ៣។ បណ្ឌិតគប្បីរាប់ ដូចជាការរាប់នូវបច្ចនីយានុលោម ក្នុងកុសលត្តិកៈដែរ។

ចប់ បច្ចនីយានុលោម។

ចប់ បច្ចយវារៈ។

**និស្សយវារៈ**

[១០៨] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ អាស្រ័យវិបាកក្ខន្ធ១។

[១០៩] ក្នុងហេតុប្បច្ច័យ មានវារៈ១៧ ក្នុងនហេតុប្បច្ច័យ មានវារៈ១២ ក្នុងនោវិគតប្បច្ច័យ មានវារៈ៥ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៥ ព្រោះហេតុប្បច្ច័យ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ៧ ព្រោះនហេតុប្បច្ច័យ ក្នុងអវិគតប្បច្ច័យ មានវារៈ១២។

ចប់ និស្សយវារៈ។

**សំសដ្ឋវារៈ**

[១១០] វិបាកធម៌ ច្រឡំដោយវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ ច្រឡំដោយវិបាកក្ខន្ធ១។ សេចក្តីបំប្រួញ។ បទទាំងអស់ បណ្ឌិតគប្បីដឹងដោយពិស្តារចុះ។

[១១១] ក្នុងហេតុប្បច្ច័យ មានវារៈ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៣

ក្នុងនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ២ ក្នុងកម្មប្បច្ច័យ មានវារៈ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ១ ក្នុងអាហារប្បច្ច័យ មានវារៈ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៣ ក្នុងឈានប្បច្ច័យ មានវារៈ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ៣ ក្នុងវិគតប្បច្ច័យ មានវារៈ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ៣។ សេចក្តីបំប្រួញ។ បណ្ឌិត គប្បីរាប់ដូចជាការរាប់ ក្នុងកុសលត្តិកៈដែរ។

ចប់ អនុលោម។

[១១២] វិបាកធម៌ ចុះឡំដោយវិបាកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ៣ ចុះឡំដោយអហេតុកវិបាកក្ខន្ធ១ ខន្ធ២ ចុះឡំដោយខន្ធ២។ បទទាំងអស់ បណ្ឌិតចែកផងចុះ។

[១១៣] ក្នុងនហេតុប្បច្ច័យ មានវារៈ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ២ ក្នុងនឈានប្បច្ច័យ មានវារៈ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៣។ បណ្ឌិតគប្បីរាប់ ដូចជាការរាប់នូវបច្ចនីយៈ ក្នុងកុសលត្តិកៈដែរ។

ចប់ បច្ចនីយៈ។

[១១៤] ក្នុងនអធិបតិប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ។ សេចក្តីបំប្រួញ។ ... ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៣។ បណ្ឌិតគប្បីរាប់ ដូចជាការរាប់នូវអនុលោមបច្ចនីយៈ ក្នុងកុសលត្តិកៈដែរ។

ចប់ អនុលោមបច្ចនីយៈ។

[១១៥] ក្នុងអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះនហេតុប្បច្ច័យ ... ក្នុងអវិគតប្បច្ច័យ មានវារៈ៣។ បណ្ឌិត គប្បីរាប់ ដូចជាការរាប់នូវបច្ចនីយានុលោម ក្នុងកុសលត្តិកៈដែរ។

ចប់ បច្ចនីយានុលោម។

ចប់ សំសដ្ឋវារៈ។

## សម្បយុត្តវារៈ

[១១៦] វិបាកធម៌ បុកបដោយវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ៣ បុកបដោយវិបាកក្ខន្ធ១។ ក្នុងនហេតុប្បច្ច័យ មានវារៈ៣។ ក្នុងនអធិបតិប្បច្ច័យ មានវារៈ៣ ព្រោះហេតុប្បច្ច័យ។ ក្នុងអារម្មណប្បច្ច័យ មានវារៈ៣ ព្រោះនហេតុប្បច្ច័យ។

ចប់ សម្បយុត្តវារៈ។

## បញ្ហាវារៈ

[១១៧] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយហេតុប្បច្ច័យ គឺពួកវិបាកជាហេតុ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ពួកវិបាកជាហេតុ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ដោយហេតុប្បច្ច័យ។ វិបាកធម៌ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ (ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាបុកុតី) ដោយហេតុប្បច្ច័យ គឺពួកវិបាក ជាហេតុ ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ពួកវិបាក ជាហេតុ ជាបច្ច័យ នៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយហេតុប្បច្ច័យ។ វិបាកធម៌ជាបច្ច័យ នៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយហេតុប្បច្ច័យ គឺពួកវិបាកជាហេតុ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ពួកវិបាក ជាហេតុ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយហេតុប្បច្ច័យ។

[១១៨] វិបាកធម្មធម៌ (ធម៌មានវិបាកជាប្រក្រតី) ជាបច្ច័យ នៃវិបាកធម្មធម៌ ដោយហេតុប្បច្ច័យ គឺវិបាកធម្មធម៌ទាំងឡាយ ជាហេតុ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយហេតុប្បច្ច័យ គឺវិបាកធម្មធម៌ទាំងឡាយ ជាហេតុ ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យ នៃវិបាកធម្មធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយហេតុប្បច្ច័យ គឺវិបាកធម្មធម៌ទាំងឡាយ ជាហេតុ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។

[១១៩] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយហេតុប្បច្ច័យ គឺនេវវិបាកនវិបាកធម្មធម៌ទាំងឡាយ ជាហេតុ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ។

[១២០] វិបាកធម៌ ជាបច្ច័យ នៃវិបាកធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គល ឃើញច្បាស់នូវវិបាកក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ក៏ត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវវិបាកក្ខន្ធនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង កាលបើកុសល និងអកុសល រលត់ហើយ វិបាក ទើបកើតឡើង ព្រោះអំពើនោះជាអារម្មណ៍។ វិបាកធម៌ជាបច្ច័យ នៃវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ គឺពួកសេក្ខបុគ្គលពិចារណាឃើញនូវផល ក៏ឃើញច្បាស់នូវវិបាកក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន តែងត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវវិបាកក្ខន្ធនោះ ទើបកើតឡើង។បេ។ ទោមនស្សកើតឡើង ពួកសេក្ខបុគ្គល ដឹងនូវចិត្តនៃបុគ្គលដែលប្រកបដោយវិបាកចិត្ត ដោយចេតោបរិយញ្ញាណ។ វិបាកក្ខន្ធទាំងឡាយ ជាបច្ច័យនៃចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ។ វិបាកធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអាម្មណប្បច្ច័យ គឺព្រះអរហន្ត ពិចារណាឃើញនូវផល គឺឃើញច្បាស់ នូវវិបាកក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដឹងនូវ

ចិត្ត នៃបុគ្គលដែលប្រកបដោយវិបាកចិត្ត ដោយចេតោបរិយញ្ញាណ។ វិបាកក្ខន្ធទាំងឡាយ ជាបច្ច័យ នៃការពិចារណានូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ។

[១២១] វិបាកធម្មធម៌ ជាបច្ច័យ នៃវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ពិចារណានូវអំពើជាកុសលនោះ ពិចារណានូវអំពើជាកុសលទាំងឡាយ ដែលខ្លួនធ្លាប់សន្សំល្អហើយក្នុងកាលមុន ចេញចាកឈាន ពិចារណាឈាន ពួកសេក្ខបុគ្គល ពិចារណានូវគោត្រភូ ពិចារណានូវវោទានៈ ពួកសេក្ខបុគ្គល ចេញចាកមគ្គ ពិចារណានូវមគ្គ ពួកសេក្ខបុគ្គល ពិចារណានូវពួកកិលេស ដែលខ្លួនលះបង់ហើយ ពិចារណានូវពួកកិលេស ដែលខ្លួនសង្កត់សង្កិនហើយ ដឹងនូវពួកកិលេស ដែលខ្លួនធ្លាប់សន្សំទុកហើយ ក្នុងកាលមុន ឃើញច្បាស់នូវវិបាកធម្មធម្មក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន តែងត្រកអរ រីករាយ រាគៈ ប្រារព្ធនូវខន្ធនោះ ទើបកើតឡើង។បេ។ ទោមនស្សកើតឡើង ពួកសេក្ខបុគ្គល ដឹងនូវចិត្តនៃបុគ្គលដែលប្រកបដោយវិបាកធម្មធម្មចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនកុសល ជាបច្ច័យ នៃវិញ្ញាណញ្ចាយតនកុសល ដោយអារម្មណប្បច្ច័យ។បេ។ អាកិញ្ចញ្ញាយតនកុសល ជាបច្ច័យ នៃនេវសញ្ញានាសញ្ញាយតនកុសល ដោយអារម្មណប្បច្ច័យ វិបាកធម្មធម្មក្ខន្ធទាំងឡាយ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យ នៃវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឃើញច្បាស់ នូវវិបាកធម្មធម្មក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន តែងត្រកអរ រីករាយ រាគៈ ប្រារព្ធនូវខន្ធនោះ ទើបកើតឡើង។បេ។ ទោមនស្សកើតឡើង កាលបើកុសល និងអកុសល រលត់ហើយ វិបាកកើតឡើង ព្រោះអំពើនោះជាអារម្មណ៍ អាកាសានញ្ចាយតនកុសល ជាបច្ច័យ នៃវិញ្ញាណញ្ចាយតនវិបាក ដោយអារម្មណប្បច្ច័យ។បេ។ អាកិញ្ចញ្ញាយតនកុសល ជាបច្ច័យ នៃនេវសញ្ញានាសញ្ញាយតនវិបាក ដោយអារម្មណប្បច្ច័យ វិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ ព្រះអរហន្ត ចេញចាកមគ្គ ពិចារណាមគ្គ ពិចារណានូវអំពើទាំងឡាយ ដែលខ្លួន

សន្សំហើយ ក្នុងកាលមុន ព្រះអរហន្ត ពិចារណានូវកិលេសទាំងឡាយ ដែលខ្លួនលះបង់ហើយ ដឹងនូវកិលេសទាំងឡាយ ដែលខ្លួនសន្សំទុក ក្នុងកាលមុន ឃើញច្បាស់ នូវវិបាកធម្មធម្មក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដឹងនូវចិត្ត នៃបុគ្គលដែលប្រកបដោយវិបាកធម្មធម្មចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនកុសល ជាបច្ច័យ នៃវិញ្ញាណញ្ចាយតនកិរិយា ដោយអារម្មណប្បច្ច័យ។បេ។ អាកិញ្ចញ្ញាយតនកុសល ជាបច្ច័យ នៃនេវសញ្ញានាសញ្ញាយតនកិរិយា ដោយអារម្មណប្បច្ច័យ វិបាកធម្មធម្មក្ខន្ធទាំងឡាយ ជាបច្ច័យនៃការពិចារណា នូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ។

[១២២] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ គឺព្រះអរហន្ត ពិចារណានូវព្រះនិព្វាន ព្រះនិព្វាន ជាបច្ច័យនៃការពិចារណា ដោយអារម្មណប្បច្ច័យ។ ព្រះអរហន្ត ឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន សោតៈ ... ឃានៈ ជិវ្ហា កាយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ វត្ថុ ... ឃើញច្បាស់ នូវនេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ឃើញច្បាស់នូវរូប ដោយទិព្វចក្ខុ ឮសំឡេង ដោយទិព្វសោតធាតុ ដឹងនូវចិត្តនៃបុគ្គល ដែលប្រកបដោយនេវវិបាកនវិបាកធម្មធម្មចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនកិរិយា ជាបច្ច័យ នៃវិញ្ញាណញ្ចាយតនកិរិយា ដោយអារម្មណប្បច្ច័យ។បេ។ អាកិញ្ចញ្ញាយតនកិរិយា ជាបច្ច័យ នៃនេវសញ្ញានាសញ្ញាយតនកិរិយា ដោយអារម្មណប្បច្ច័យ នេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ ជាបច្ច័យ នៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអារម្មណប្បច្ច័យ គឺព្រះនិព្វាន ជាបច្ច័យនៃផល ដោយអារម្មណប្បច្ច័យ ពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី ពិចារណាឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន តែងត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង។បេ។ ទោមនស្ស កើតឡើង កាលបើកុសល និងអកុសល រលត់ហើយ

វិបាកទើបកើតឡើង ព្រោះអំពើនោះ ជាបច្ច័យ សោតៈ ... ឃានៈ ជិវ្ហា កាយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ វត្ថុ ... ពួកសេក្ខបុគ្គល ពិចារណាឃើញច្បាស់ នូវនេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវខន្ធនោះ ទើបកើតឡើង។បេ។ ទោមនស្សកើតឡើង កាលបើកុសល និងអកុសល រលត់ហើយ វិបាកកើតឡើង ព្រោះអំពើនោះជាអារម្មណ៍ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ។បេ។ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ គឺពួកសេក្ខបុគ្គល ពិចារណានូវព្រះនិព្វាន ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ និងមគ្គ ដោយអារម្មណប្បច្ច័យ។ ពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី ពិចារណាឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន តែងត្រេកអរ រីករាយ ចំពោះចក្ខុនោះ។បេ។ ទោមនស្សកើតឡើង សោតៈ ...។បេ។ ពួកសេក្ខបុគ្គល ពិចារណាឃើញច្បាស់ នូវនេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន តែងត្រេកអរ រីករាយ ឃើញច្បាស់នូវរូប ដោយទិព្វចក្ខុ ឮសំឡេង ដោយទិព្វសោតធាតុ ដឹងនូវចិត្តនៃបុគ្គល ដែលប្រកបដោយនេវវិបាកនវិបាកធម្មធម្មចិត្ត ដោយចេតោបរិយញ្ញាណ នេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយជាបច្ច័យ នៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ។

[១២៣] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់សហជាតាធិបតិ គឺវិបាកាធិបតិ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធដោយអធិបតិប្បច្ច័យ។ វិបាកធម៌ ជាបច្ច័យ នៃវិបាកធម្មធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់អារម្មណាធិបតិ គឺពួកសេក្ខបុគ្គល ធ្វើផលឲ្យជាទីគោរព ទើបពិចារណា ធ្វើវិបាកក្ខន្ធទាំងឡាយ ឲ្យជាទីគោរព ទើបត្រេកអរ រីករាយ រាគៈ ធ្វើខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង។បេ។ វិបាកធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ ឯអារម្មណាធិបតិ ព្រះអរហន្ត ធ្វើផលឲ្យជាទីគោរព ទើប

ពិចារណា។ ឯសហជាតាធិបតិ គឺវិបាកាធិបតិ ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ។ វិបាកធម៌ ជាបច្ច័យ នៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយអធិបតិប្បច្ច័យ គឺបានដល់សហជាតាធិបតិ គឺវិបាកាធិបតិ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។

[១២៤] វិបាកធម្មធម៌ ជាបច្ច័យ នៃវិបាកធម្មធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ ឯអារម្មណាធិបតិ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើអំពើទាំងនោះ ឲ្យជាទីគោរព ទើបពិចារណា ធ្វើអំពើទាំងឡាយ ដែលខ្លួនសន្សំល្អហើយ ក្នុងកាលមុន ឲ្យជាទីគោរព ទើបពិចារណា ចេញចាកឈាន ធ្វើឈានឲ្យជាទីគោរព ទើបពិចារណា ពួកសេក្ខបុគ្គល ធ្វើគោត្រភូ ឲ្យជាទីគោរព ទើបពិចារណា ធ្វើវោទានៈ ឲ្យជាទីគោរព ទើបពិចារណា ពួកសេក្ខបុគ្គល ចេញចាកមគ្គ ធ្វើមគ្គឲ្យជាទីគោរព ទើបពិចារណា ធ្វើវិបាកធម្មធម្មក្ខន្ធទាំងឡាយឲ្យជាទីគោរព ទើបត្រេកអរ រីករាយ រាគៈ ធ្វើខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង។បេ។ ឯសហជាតាធិបតិ វិបាកធម្មធម្មាធិបតិ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ ឯអារម្មណាធិបតិ គឺព្រះអរហន្ត ចេញចាកមគ្គ ធ្វើមគ្គឲ្យជាទីគោរព ទើបពិចារណា។ ឯសហជាតាធិបតិ គឺវិបាកធម្មធម្មាធិបតិ ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យ នៃវិបាកធម្មធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយអធិបតិប្បច្ច័យ គឺបានដល់សហជាតាធិបតិ គឺវិបាកធម្មធម្មាធិបតិ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។

[១២៥] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់អារម្មណាធិបតិ និងសហជាតាធិបតិ។ ឯ

អារម្មណាធិបតិ គឺព្រះអរហន្ត ធ្វើនូវព្រះនិព្វាន ឲ្យជាទីគោរព ទើបពិចារណា។ ៦ សហជាតាធិបតិ គឺនេវវិបាកនវិបាកធម្មធម្មាធិបតិ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃវិបាកធម្មធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់អារម្មណាធិបតិ ព្រះនិព្វាន ជាបច្ច័យនៃផល ដោយអធិបតិប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃវិបាកធម្មធម៌ ដោយអធិបតិប្បច្ច័យ គឺបានដល់អារម្មណាធិបតិ គឺពួកសេក្ខបុគ្គល ធ្វើព្រះនិព្វាន ឲ្យជាទីគោរព ទើបពិចារណា ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ និងមគ្គ ដោយអធិបតិប្បច្ច័យ ពួកសេក្ខបុគ្គល ធ្វើចក្ខុឲ្យជាទីគោរព ទើបត្រេកអរ រីករាយ រាគៈ ធ្វើចក្ខុនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង។បេ។ សោតៈ ...។បេ។ ពួកសេក្ខបុគ្គល ធ្វើនេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ ធ្វើខន្ធទាំងនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង។បេ។

[១២៦] វិបាកធម៌ ជាបច្ច័យ នៃវិបាកធម៌ ដោយអនន្តរប្បច្ច័យ គឺពួកវិបាកក្ខន្ធមុនៗ ជាបច្ច័យ នៃពួកវិបាកក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ បញ្ចវិញ្ញាណ ជាបច្ច័យនៃវិបាកមនោធាតុ ដោយអនន្តរប្បច្ច័យ វិបាកមនោធាតុ ជាបច្ច័យនៃវិបាកមនោវិញ្ញាណធាតុ ដោយអនន្តរប្បច្ច័យ។ វិបាកធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអនន្តរប្បច្ច័យ គឺភវង្គៈ ជាបច្ច័យនៃអាវជ្ជនៈ ដោយអនន្តរប្បច្ច័យ វិបាកមនោវិញ្ញាណធាតុ ជាបច្ច័យនៃកិរិយាមនោវិញ្ញាណធាតុ ដោយអនន្តរប្បច្ច័យ។

[១២៧] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអនន្តរប្បច្ច័យ គឺពួកវិបាកធម្មធម្មក្ខន្ធមុនៗ ជាបច្ច័យ នៃពួកវិបាកធម្មធម្មក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ជាបច្ច័យនៃគោត្រភូ អនុលោម ជាបច្ច័យនៃវោទានៈ គោត្រភូ ជាបច្ច័យនៃមគ្គ វោទានៈ ជាបច្ច័យនៃមគ្គ ដោយអនន្តរប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យ នៃវិបាកធម៌ ដោយអនន្តរប្បច្ច័យ គឺពួកវិបាក

ធម្មធម្មក្ខន្ធ ជាបច្ច័យនៃវុដ្ឋានៈ មគ្គ ជាបច្ច័យនៃផល អនុលោម របស់ពួក សេក្ខបុគ្គល ជាបច្ច័យ នៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនកុសល របស់បុគ្គលដែលចេញចាកនិរោធ ជាបច្ច័យ នៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ។

[១២៨] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនេវវិបាកនវិបាកធម្មធម្មក្ខន្ធមុនៗ ជាបច្ច័យ នៃពួកនេវវិបាកនវិបាកធម្មធម្មក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអនន្តរប្បច្ច័យ គឺអាវជ្ជនៈ ជាបច្ច័យនៃបញ្ចវិញ្ញាណ ដោយអនន្តរប្បច្ច័យ ពួកនេវវិបាកនវិបាកធម្មធម្មក្ខន្ធ ជាបច្ច័យនៃវុដ្ឋានៈ អនុលោម របស់ព្រះអរហន្ត ជាបច្ច័យនៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនកិរិយា របស់បុគ្គលដែលចេញពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃវិបាកធម្មធម៌ ដោយអនន្តរប្បច្ច័យ គឺអាវជ្ជនៈ ជាបច្ច័យនៃពួកវិបាកធម្មធម្មក្ខន្ធ ដោយអនន្តរប្បច្ច័យ។

[១២៩] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយសមនន្តរប្បច្ច័យ គឺប្រហែលគ្នានឹងអនន្តរប្បច្ច័យដែរ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយសហជាតប្បច្ច័យ គឺវិបាកក្ខន្ធ១ (ជាបច្ច័យ) នៃវិបាកក្ខន្ធ៣។បេ។ ខន្ធ៣។

[១៣០] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយសហជាតប្បច្ច័យ គឺខន្ធ៣។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយសហជាតប្បច្ច័យ គឺនេវវិបាកនវិបាកធម្មធម្មក្ខន្ធ១ មហាភូត១ ... ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត១ របស់ពួកអសញ្ញសត្វ។

[១៣១] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃវិបាកធម៌ ដោយសហជាតប្បច្ច័យ គឺវត្ថុ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ។

[១៣២] វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃវិបាកធម៌ ដោយសហជាតប្បច្ច័យ គឺវិបាកក្ខន្ធ១ក្តី វត្ថុក្តី (ជាបច្ច័យ) នៃខន្ធ៣ ក្នុងខណៈនៃបដិសន្ធិ។ វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយសហជាតប្បច្ច័យ គឺពួកវិបាកក្ខន្ធក្តី ពួកមហាភូតក្តី (ជាបច្ច័យ) នៃពួកចិត្តសមុដ្ឋានរូប។

[១៣៣] វិបាកធម្មធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយសហជាតប្បច្ច័យ គឺពួកវិបាកធម្មធម្មក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ។

[១៣៤] វិបាកធម៌ ជាបច្ច័យ នៃវិបាកធម៌ ដោយអញ្ញមញ្ញប្បច្ច័យ គឺវិបាកក្ខន្ធ១ ក្នុងខណៈនៃបដិសន្ធិ ...។ វិបាកធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអញ្ញមញ្ញប្បច្ច័យ គឺពួកវិបាកក្ខន្ធ ជាបច្ច័យនៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយអញ្ញមញ្ញប្បច្ច័យ គឺវិបាកក្ខន្ធ១ ជាបច្ច័យនៃខន្ធ៣ផង នៃវត្ថុផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ។

[១៣៥] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអញ្ញមញ្ញប្បច្ច័យ គឺវិបាកធម្មធម្មក្ខន្ធ១ (ជាបច្ច័យ) នៃខន្ធ៣ ខន្ធ២ (ជាបច្ច័យ) នៃខន្ធ២។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអញ្ញមញ្ញប្បច្ច័យ គឺនេវវិបាកនវិបាកធម្មធម្មក្ខន្ធ១ (ជាបច្ច័យ) នៃខន្ធ៣ ខន្ធ២ (ជាបច្ច័យ) នៃខន្ធ២។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអញ្ញមញ្ញប្បច្ច័យ គឺវត្ថុ (ជាបច្ច័យ) នៃពួកវិបាកក្ខន្ធក្នុងខណៈនៃបដិសន្ធិ។

[១៣៦] វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី (ជាបច្ច័យ) នៃវិបាកធម៌ គឺវិបាកក្ខន្ធ១ក្តី វត្ថុក្តី (ជាបច្ច័យ) នៃខន្ធ៣ ក្នុងខណៈនៃបដិសន្ធិ។ បញ្ហា៧។

[១៣៧] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយនិស្សយប្បច្ច័យ គឺខន្ធ៣។ វិបាកធម្មធម៌ (ជាបច្ច័យ) នៃវិបាកធម្មធម៌ គឺខន្ធ៣។ នេវវិបាកនវិបាកធម្ម

ធម៌ (ជាបច្ច័យ) នៃនេវវិបាកនវិបាកធម្មធម៌។បេ។ នេវវិបាកនវិបាកធម្មធម៌ (ជាបច្ច័យ) នៃវិបាកធម៌ គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយនិស្សយប្បច្ច័យ។បេ។ កាយាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ វត្ថុ (ជាបច្ច័យ) នៃពួកវិបាកក្ខន្ធ វត្ថុ (ជាបច្ច័យ) នៃពួកវិបាកក្ខន្ធក្នុងខណៈនៃបដិសន្ធិ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃវិបាកធម្មធម៌ ដោយនិស្សយប្បច្ច័យ គឺវត្ថុ (ជាបច្ច័យ) នៃពួកវិបាកធម្មធម្មក្ខន្ធ។

[១៣៨] វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃវិបាកធម៌ ដោយនិស្សយប្បច្ច័យ គឺខន្ធ១ ដែលច្រឡំដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី។បេ។ កាយាយតនៈក្តី វិបាកក្ខន្ធ១ក្តី វត្ថុក្តី (ជាបច្ច័យ) នៃខន្ធ៣ វិបាកក្ខន្ធ១ក្តី វត្ថុក្តី ក្នុងខណៈនៃបដិសន្ធិ។ វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយនិស្សយប្បច្ច័យ គឺពួកវិបាកក្ខន្ធក្តី ពួកមហាភូតក្តី។ សេចក្តីបំប្រួញ។ ក្នុងខណៈនៃបដិសន្ធិ ...។ វិបាកធម្មធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃវិបាកធម្មធម៌ ដោយនិស្សយប្បច្ច័យ គឺវិបាកធម្មធម្មក្ខន្ធ១ក្តី វត្ថុក្តី។ វិបាកធម្មធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយនិស្សយប្បច្ច័យ គឺពួកវិបាកធម្មធម្មក្ខន្ធក្តី ពួកមហាភូតក្តី (ជាបច្ច័យ) នៃពួកចិត្តសមុដ្ឋានរូប។ បញ្ហា១៣។

[១៣៩] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។ បកតូបនិស្ស័យ គឺកាយិកសុខ ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ កាយិកទុក្ខ ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ផលសមាបត្តិ ជាបច្ច័យ នៃកាយិកសុខ ដោយឧបនិស្សយប្បច្ច័យ។ វិបាកធម៌ (ជាបច្ច័យ) នៃវិបាកធម្មធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អារម្មណូបនិស្ស័យ និងបកតូបនិស្ស័យ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យកាយិកសុខ ហើយឲ្យទាន សមាទានសីល។បេ។ បំបែកសង្ឃ អាស្រ័យកាយិកទុក្ខ ហើយឲ្យទាន សមាទានសីល។បេ។ បំបែកសង្ឃ កាយិកសុខ ...

កាយិកទុក្ខ (ជាបច្ច័យ) នៃសទ្ធា។បេ។ ជាបច្ច័យនៃសេចក្ដីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ។ វិបាកធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។ បកតូបនិស្ស័យ គឺព្រះអរហន្ត អាស្រ័យកាយិកសុខ ធ្វើកិរិយាសមាបត្តិ ដែលមិនទាន់កើត ឲ្យកើតឡើង ចូលកាន់កិរិយាសមាបត្តិ ដែលកើតឡើងហើយ ពិចារណាឃើញច្បាស់នូវសង្ខារទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន អាស្រ័យកាយិកទុក្ខ ធ្វើកិរិយាសមាបត្តិ ដែលមិនទាន់កើត ឲ្យកើតឡើង ចូលកាន់កិរិយាសមាបត្តិ ដែលកើតឡើងហើយ។

[១៤០] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យសទ្ធា ហើយឲ្យទាន។បេ។ ដំឡើងមានះ ប្រកាន់ទិដ្ឋិ សីល ... សុតៈ ... ចាគៈ ... អាស្រ័យបញ្ញា ហើយឲ្យទាន។បេ។ ដំឡើងមានះ ប្រកាន់ទិដ្ឋិ រាគៈ ... ទោសៈ មោហៈ មានះ ទិដ្ឋិ ... អាស្រ័យសេចក្ដីប្រាថ្នា ហើយឲ្យទាន។បេ។ ធ្វើសមាបត្តិឲ្យកើតឡើង សម្លាប់សត្វ។បេ។ បំបែកសង្ឃ។បេ។ សទ្ធា។បេ។ សេចក្ដីប្រាថ្នា (ជាបច្ច័យ) នៃសទ្ធា នៃសីល។បេ។ ជាបច្ច័យនៃសេចក្ដីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃបឋមជ្ឈាន (ជាបច្ច័យ) នៃបឋមជ្ឈាន។បេ។ បរិកម្ម នៃនេវសញ្ញានាសញ្ញាយតនៈ (ជាបច្ច័យ) នៃនេវសញ្ញានាសញ្ញាយតនៈ បឋមជ្ឈាន (ជាបច្ច័យ) នៃទុតិយជ្ឈាន។បេ។ អាកិញ្ចញ្ញាយតនៈ ជាបច្ច័យ នៃនេវសញ្ញានាសញ្ញាយតនៈ ដោយឧបនិស្សយប្បច្ច័យ។បេ។ បរិកម្មនៃមគ្គទី១ (ជាបច្ច័យ) នៃមគ្គទី១។បេ។ បរិកម្មនៃមគ្គទី៤ (ជាបច្ច័យ) នៃមគ្គទី៤ មគ្គទី១ (ជាបច្ច័យ) នៃមគ្គទី២ មគ្គទី២ (ជាបច្ច័យ) នៃមគ្គទី៣ មគ្គទី៣ ជាបច្ច័យ នៃមគ្គទី៤ ដោយឧបនិស្សយប្បច្ច័យ ពួកសេក្ខបុគ្គល អាស្រ័យមគ្គហើយ ធ្វើកុសលសមាបត្តិ ដែលមិនទាន់កើត ឲ្យកើតឡើង។បេ។ មគ្គ (ជាបច្ច័យ) នៃអត្ថប្បដិសម្ភិទា របស់ពួកសេក្ខបុគ្គល។បេ។ ជាបច្ច័យ នៃសេចក្ដីឈ្លាសក្នុងឋានាឋានៈ ដោយឧបនិស្សយប្បច្ច័យ បាណាតិបាត (ជាបច្ច័យ) នៃ

បាណាតិបាត។បេ។ ជាបច្ច័យនៃមិច្ឆាទិដ្ឋិ ដោយឧបនិស្សយប្បច្ច័យ។បេ។ មិច្ឆាទិដ្ឋិ (ជាបច្ច័យ) នៃមិច្ឆាទិដ្ឋិ។បេ។ នៃព្យាបាទ មាតុឃាតកម្ម ជាបច្ច័យនៃមាតុឃាតកម្ម ដោយឧបនិស្សយប្បច្ច័យ។បេ។ ជាបច្ច័យនៃនិយតមិច្ឆាទិដ្ឋិ ដោយឧបនិស្សយប្បច្ច័យ និយតមិច្ឆាទិដ្ឋិ (ជាបច្ច័យ) នៃនិយតមិច្ឆាទិដ្ឋិ ជាបច្ច័យនៃសង្ឃភេទកម្ម ដោយឧបនិស្សយប្បច្ច័យ។បេ។

[១៤១] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យសទ្ធា ធ្វើខ្លួនឲ្យក្តៅ ឲ្យក្តៅសព្វ រងនូវទុក្ខដែលមានការស្វែងរកជាមូល។បេ។ អាស្រ័យសេចក្តីប្រាថ្នា ធ្វើខ្លួនឲ្យក្តៅ ឲ្យក្តៅសព្វ។បេ។ សទ្ធា។បេ។ សេចក្តីប្រាថ្នា ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ កុសល និងអកុសល ជាបច្ច័យនៃកម្មវិបាក ដោយឧបនិស្សយប្បច្ច័យ មគ្គ ជាបច្ច័យ នៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អារម្មណូបនិស្ស័យ និងបកតូបនិស្ស័យ។ បកតូបនិស្ស័យ គឺព្រះអរហន្ត អាស្រ័យមគ្គ ធ្វើកិរិយាសមាបត្តិ ដែលមិនទាន់កើត ឲ្យកើតឡើង ចូលកាន់កិរិយាសមាបត្តិ ដែលកើតឡើងហើយ ពិចារណាឃើញច្បាស់នូវសង្ខារទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន។បេ។ មគ្គ ជាបច្ច័យនៃអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា និងឋានាឋានកោសល្ល របស់ព្រះអរហន្ត ដោយឧបនិស្សយប្បច្ច័យ។

[១៤២] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។ បកតូបនិស្ស័យ គឺព្រះអរហន្ត អាស្រ័យរដូវ ... ភោជន ... សេនាសនៈ ធ្វើកិរិយាសមាបត្តិ ដែលមិនទាន់កើត ឲ្យកើតឡើង ចូលកាន់កិរិយាសមាបត្តិ ដែលកើតឡើងហើយ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អារម្មណូបនិស្ស័យ អនន្តរូប

និស្ស័យ និងបកតូបនិស្ស័យ។ បកតូបនិស្ស័យ គឺរដូវ... ភោជន ... សេនាសនៈ ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយឧបនិស្សយប្បច្ច័យ គឺបានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យរដូវ ហើយឲ្យទាន។បេ។ បំបែកសង្ឃ អាស្រ័យភោជន ... សេនាសនៈ ហើយឲ្យទាន។បេ។ បំបែកសង្ឃ រដូវ ... ភោជន ... សេនាសនៈ (ជាបច្ច័យ) នៃសទ្ធា។បេ។ ជាបច្ច័យ នៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ។

[១៥៣] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយបុរេជាតប្បច្ច័យ គឺបានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺព្រះអរហន្ត (ពិចារណាឃើញ) នូវចក្ខុ ថាមិនទៀង។បេ។ នូវកាយ នូវរូបទាំងឡាយ។បេ។ នូវផ្សព្វទាំងឡាយ នូវវត្ថុ ថាមិនទៀង។បេ។ នូវរូប ដោយទិព្វចក្ខុ។បេ។ នូវសំឡេង ដោយទិព្វសោតធាតុ។បេ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ ដោយបុរេជាតប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយបុរេជាតប្បច្ច័យ គឺបានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី ពិចារណាឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ហើយត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង។បេ។ទោមនស្ស កើតឡើង កាលបើកុសល និងអកុសល រលត់ហើយ វិបាកកើតឡើង ព្រោះអំពើនោះជាអារម្មណ៍ នូវសោតៈ។បេ។ នូវវត្ថុ ថាមិនទៀង។បេ។ (វិបាក) កើតឡើង ព្រោះអំពើនោះជាអារម្មណ៍ រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយបុរេជាតប្បច្ច័យ។បេ។ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ។បេ។ កាយាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យ នៃពួកវិបាកក្ខន្ធ ដោយបុរេជាតប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយបុរេជាតប្បច្ច័យ គឺ

បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត។ អារម្មណបុរេជាត គឺពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី (ពិចារណាឃើញ) នូវចក្ខុ។បេ។ រាគៈ ប្រារព្ធ ទើបកើតឡើង។បេ។ ទោមនស្សកើតឡើង នូវសោតៈ។បេ។ នូវវត្ថុ ថាមិនទៀង។បេ។ ទោមនស្ស។បេ។ នូវរូប ដោយទិព្វចក្ខុ។បេ។ នូវសំឡេង ដោយទិព្វសោតធាតុ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកវិបាកធម្មធម្មក្ខន្ធ ដោយបុរេជាតប្បច្ច័យ។

[១៩៤] វិបាកធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់បច្ឆាជាត គឺពួកវិបាកក្ខន្ធជាបច្ច័យ នៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ។

[១៩៥] វិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺនេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយបច្ឆាជាតប្បច្ច័យ។

[១៩៦] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអាសេវនប្បច្ច័យ គឺពួកវិបាកធម្មធម្មក្ខន្ធមុនៗ (ជាបច្ច័យ) នៃពួកវិបាកធម្មធម្មក្ខន្ធក្រោយៗ អនុលោម (ជាបច្ច័យ) នៃគោត្រភូ អនុលោម (ជាបច្ច័យ) នៃវោទានៈ គោត្រភូ (ជាបច្ច័យ) នៃមគ្គ វោទានៈ ជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ។

[១៩៧] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអាសេវនប្បច្ច័យ គឺ (ពួកខន្ធ) មុនៗ។បេ។ ជាបច្ច័យ ដោយអាសេវនប្បច្ច័យ។

[១៩៨] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយកម្មប្បច្ច័យ គឺវិបាកចេតនា ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ វិបាកចេតនា ក្នុងខណៈនៃបដិសន្ធិ។ វិបាកធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយកម្មប្បច្ច័យ គឺវិបាកចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ វិបាកចេតនា ក្នុងខណៈនៃបដិសន្ធិ (ជាបច្ច័យ) នៃពួកកដត្តារូប។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយកម្មប្បច្ច័

យ គឺវិបាកចេតនា (ជាបច្ច័យ) នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង វិបាកចេតនា (ជាបច្ច័យ) នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ។

[១៤៩] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយកម្មប្បច្ច័យ គឺវិបាកធម្មធម្មចេតនា (ជាបច្ច័យ) នៃពួកសម្បយុត្តកក្ខន្ធ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយកម្មប្បច្ច័យ បានដល់នានាខណិកា គឺពួកវិបាកធម្មធម្មចេតនា ជាបច្ច័យ នៃពួកវិបាកក្ខន្ធ ដោយកម្មប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយកម្មប្បច្ច័យ គឺបានដល់សហជាតានានាខណិកា។ សហជាតា គឺវិបាកធម្មធម្មចេតនា (ជាបច្ច័យ) នៃពួកចិត្តសមុដ្ឋានរូប។ ឯនានាខណិកា គឺវិបាកធម្មធម្មចេតនា (ជាបច្ច័យ) នៃពួកកដត្តារូប។ វិបាកធម្មធម៌ (ជាបច្ច័យ) នៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង គឺបានដល់នានាខណិកា គឺវិបាកធម្មធម្មចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយកម្មប្បច្ច័យ គឺវិបាកធម្មធម្មចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ។

[១៥០] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយកម្មប្បច្ច័យ គឺនេវវិបាកនវិបាកធម្មធម្មចេតនា (ជាបច្ច័យ) នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង។

[១៥១] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយវិបាកប្បច្ច័យ គឺវិបាកខន្ធ១ (ជាបច្ច័យ) នៃខន្ធ៣ ក្នុងខណៈនៃបដិសន្ធិ ...។ វិបាកធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយវិបាកប្បច្ច័យ គឺពួកវិបាកក្ខន្ធ (ជាបច្ច័យ) នៃពួកចិត្តសមុដ្ឋានរូប ពួកវិបាកក្ខន្ធ (ជាបច្ច័យ) នៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌

ផង ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ១ (ជាបច្ច័យ) នៃខន្ធ៣ផង នៃពួកចិត្តសមុដ្ឋានរូបផង វិបាកក្ខន្ធ១ ជាបច្ច័យនៃខន្ធ៣ផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយវិបាកប្បច្ច័យ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអាហារប្បច្ច័យ គឺវិបាកាហារ (ជាបច្ច័យ) នៃពួកសម្បយុត្តកក្ខន្ធ គឺខន្ធ៣។ ឯបដិសន្ធិ នៃខន្ធទាំង៣នេះ បណ្ឌិតគប្បីធ្វើចុះ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអាហារប្បច្ច័យ គឺខន្ធ៣។

[១៥២] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយអាហារប្បច្ច័យ គឺនេវវិបាកនវិបាកធម្មធម្មាហារ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ កវឡិង្ការាហារ ជាបច្ច័យនៃកាយនេះ ដោយអាហារប្បច្ច័យ។

[១៥៣] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺខន្ធ៣។ បដិសន្ធិ បណ្ឌិតគប្បីធ្វើចុះ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺខន្ធ៣។

[១៥៤] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺឥន្ទ្រិយទាំងឡាយ ជានេវវិបាកនវិបាកធម្មធម៌ (ជាបច្ច័យ) នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយឥន្ទ្រិយប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺចក្ខុន្ទ្រិយ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ។ កាយិន្ទ្រិយ។បេ។

[១៥៥] វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃវិបាកធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺចក្ខុន្ទ្រិយក្តី ចក្ខុវិញ្ញាណក្តី ជាបច្ច័យនៃពួកខន្ធដែលច្រឡំដោយចក្ខុវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ។បេ។ កាយិន្ទ្រិយក្តី កាយវិញ្ញាណក្តី ជាបច្ច័យនៃពួកខន្ធ ដែលច្រឡំដោយកាយវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ។

[១៥៦] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយឈានប្បច្ច័យ គឺខន្ធ៣។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយឈានប្បច្ច័យ គឺខន្ធ៣។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃនេវវិបាកនវិបាកធម្មធម៌ ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយ ជានេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឈានប្បច្ច័យ។

[១៥៧] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយមគ្គប្បច្ច័យ គឺខន្ធ៣។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយមគ្គប្បច្ច័យ គឺខន្ធ៣។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយ ជានេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយមគ្គប្បច្ច័យ។

[១៥៨] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយសម្បយុត្តប្បច្ច័យ គឺវិបាកក្ខន្ធ១ (ជាបច្ច័យ) នៃខន្ធ៣ ខន្ធ២ (ជាបច្ច័យ) នៃខន្ធ២ ក្នុងខណៈនៃបដិសន្ធិ ...។

[១៥៩] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយសម្បយុត្តប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយសម្បយុត្តប្បច្ច័យ។បេ។ គឺខន្ធ២ ជាបច្ច័យនៃខន្ធ២ ដោយសម្បយុត្តប្បច្ច័យ។

[១៦០] វិបាកធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាតៈ និងបច្ឆាជាតៈ។ សហជាតៈ គឺវិបាកក្ខន្ធទាំងឡាយ (ជាបច្ច័យ) នៃពួកចិត្តសមុដ្ឋានរូប វិបាកក្ខន្ធទាំងឡាយ (ជាបច្ច័យ) នៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ។ ឯបច្ឆាជាតៈ គឺវិបាកក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ។

[១៦១] វិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាតៈ និងបច្ឆាជាតៈ។ សហជាតៈ គឺពួកវិបាកធម្មធម្មក្ខន្ធ (ជាបច្ច័យ) នៃពួកចិត្តសមុដ្ឋានរូប។ ឯបច្ឆាជាតៈ គឺពួកវិបាកធម្មធម្មក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ។

[១៦២] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាតៈ បុរេជាតៈ និងបច្ឆាជាតៈ។ សហជាតៈ គឺពួកនេវវិបាកនវិបាកធម្មធម្មក្ខន្ធ (ជាបច្ច័យ) នៃពួកចិត្តសមុដ្ឋានរូប។ ឯបុរេជាតៈ គឺវត្ថុ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ។ ឯបច្ឆាជាតៈ គឺនេវវិបាកនវិបាកធម្មធម្មក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាតៈ និងបុរេជាតៈ។ សហជាតៈ គឺវត្ថុ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ។ ឯបុរេជាតៈ គឺចក្ខាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ។ បេ។ កាយាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យ នៃពួកវិបាកក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់បុរេជាតៈ គឺវត្ថុ ជាបច្ច័យនៃពួកវិបាកធម្មធម្មក្ខន្ធដោយវិប្បយុត្តប្បច្ច័យ។

[១៦៣] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអត្ថិប្បច្ច័យ គឺវិបាកក្ខន្ធ១ (ជាបច្ច័យ) នៃខន្ធ៣ វិបាកក្ខន្ធ១ ជាបច្ច័យនៃខន្ធ៣ ក្នុងខណៈនៃបដិសន្ធិ។ វិបាកធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាតៈ និងបច្ឆាជាតៈ។ សហជាតៈ គឺវិបាកក្ខន្ធទាំងឡាយ (ជាបច្ច័យ) នៃពួកចិត្តសមុដ្ឋានរូប វិបាកក្ខន្ធទាំងឡាយ (ជាបច្ច័យ) នៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ។ ឯបច្ឆាជាតៈ គឺវិបាកក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយអត្ថិប្បច្ច័យ គឺវិបាកក្ខន្ធ១ (ជាបច្ច័យ) នៃខន្ធ៣ផង នៃពួកចិត្តសមុដ្ឋានរូបផង ក្នុងខណៈនៃបដិសន្ធិ ...។

[១៦៤] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអត្ថិប្បច្ច័យ គឺខន្ធ២ ជាបច្ច័យនៃខន្ធ២ ដោយអត្ថិប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាតៈ និងបច្ឆាជាតៈ។ សហជា

តៈ គឺវិបាកធម្មធម្មក្ខន្ធទាំងឡាយ ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ។ ឯបច្ឆាជាតៈ គឺវិបាកធម្មធម្មក្ខន្ធទាំងឡាយ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយអត្ថិប្បច្ច័យ គឺវិបាកធម្មធម្មក្ខន្ធ១ (ជាបច្ច័យ) នៃខន្ធ៣ផង នៃពួកចិត្តសមុដ្ឋានរូបផង។

[១៦៥] នេវវិបាកនវិបាកធម្មធម៌ (ជាបច្ច័យ) នៃនេវវិបាកនវិបាកធម្មធម៌ បានដល់សហជាតៈ បុរេជាតៈ បច្ឆាជាតៈ អាហារ និងឥន្ទ្រិយ។ សហជាតៈ គឺនេវវិបាកនវិបាកធម្មធម្មក្ខន្ធ១ (ជាបច្ច័យ) នៃខន្ធ៣ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ២ ជាបច្ច័យនៃខន្ធ២ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ មហាភូត១ ... មហាភូតទាំងឡាយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប នៃពួកកដត្តារូប នៃពួកឧបាទារូប ដោយអត្ថិប្បច្ច័យ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... មហាភូត១ របស់ពួកអសញ្ញសត្វ។ ឯបុរេជាតៈ គឺព្រះអរហន្ត (ពិចារណាឃើញ) នូវចក្ខុ ថាមិនទៀង។បេ។ នូវសោតៈ។បេ។ នូវវត្ថុ ថាមិនទៀង។បេ។ ឃើញរូបដោយទិព្វចក្ខុ ឮសំឡេង ដោយទិព្វសោតធាតុ។បេ។ វត្ថុ ជាបច្ច័យ នៃពួកនេវវិបាកនវិបាកធម្មធម្មក្ខន្ធដោយអត្ថិប្បច្ច័យ។ ឯបច្ឆាជាតៈ គឺពួកនេវវិបាកនវិបាកធម្មធម្មក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ។ កពឡិង្ការាហារ ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ។ រូបជីវិតិន្ទ្រិយ ជាបច្ច័យ នៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាតៈ និងបុរេជាតៈ។ សហជាតៈ គឺវត្ថុ ជាបច្ច័យ នៃពួកវិបាកក្ខន្ធក្នុងខណៈនៃបដិសន្ធិ ដោយអត្ថិប្បច្ច័យ។ ឯបុរេជាតៈ គឺពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី (ពិចារណាឃើញ) នូវចក្ខុ ថាមិនទៀង។បេ។ រមែងត្រេកអរ រាគៈប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង។បេ។ ទោមនស្សកើតឡើង កាលបើកុសល និងអកុសល រលត់ហើយ វិបាក (កើតឡើង) ព្រោះអំពើនោះជាអារម្មណ៍ ... នូវសោតៈ ...។បេ។ នូវវត្ថុ ... វិបាក (កើតឡើង) ព្រោះអំពើនោះជាអារម្មណ៍ ...

រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ។បេ។ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ ចក្ខាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ កាយាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដោយអត្ថិប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអត្ថិប្បច្ច័យ បានដល់បុរេជាតៈ គឺពួកសេក្ខបុគ្គលក្តី ពួកបុថុជ្ជនក្តី (ពិចារណាឃើញ) នូវចក្ខុ ថាមិនទៀង។បេ។ រមែងតុកអរ។បេ។ ទោមនស្សកើតឡើង នូវសោត ... នូវវត្ថុ ថាមិនទៀង។បេ។ ទោមនស្សកើតឡើង ដោយទិព្វចក្ខុ។បេ។ វត្ថុជាបច្ច័យ នៃពួកវិបាកធម្មធម្មក្ខន្ធ ដោយអត្ថិប្បច្ច័យ។

[១៦៦] វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យនៃវិបាកធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាតៈ និងបុរេជាតៈ។ សហជាតៈ គឺខន្ធ១ ដែលច្រឡំដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី (ជាបច្ច័យ) នៃខន្ធ៣។បេ។ វិបាកក្ខន្ធ១ ដែលច្រឡំដោយកាយវិញ្ញាណក្តី វត្ថុក្តី (ជាបច្ច័យ) នៃខន្ធ៣ វិបាកក្ខន្ធ១ក្តី វត្ថុក្តី (ជាបច្ច័យ) នៃខន្ធ៣ ក្នុងខណៈនៃបដិសន្ធិ។ វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាតៈ បច្ឆាជាតៈ អាហារ និងឥន្ទ្រិយ។ សហជាតៈ គឺពួកវិបាកក្ខន្ធក្តី ពួកមហាភូតក្តី (ជាបច្ច័យ) នៃពួកចិត្តសមុដ្ឋានរូប ពួកវិបាកក្ខន្ធក្តី មហាភូតក្តី ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយអត្ថិប្បច្ច័យ។ ឯបច្ឆាជាតៈ គឺពួកវិបាកក្ខន្ធក្តី កពឡិង្ការាហារក្តី (ជាបច្ច័យ) នៃកាយនេះ។ ឯបច្ឆាជាតៈ គឺពួកវិបាកក្ខន្ធក្តី រូបជីវិតិន្ទ្រិយក្តី (ជាបច្ច័យ) នៃពួកកដត្តារូប។

[១៦៧] វិបាកធម្មធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យ នៃវិបាកធម្មធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាតៈ និងបុរេជាតៈ។ សហជាតៈ គឺវិបាកធម្មធម្មក្ខន្ធ១ក្តី វត្ថុក្តី (ជាបច្ច័យ) នៃខន្ធ៣។ វិបាកធម្មធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាតៈ បច្ឆាជាតៈ អាហារ និងឥន្ទ្រិយ។ សហជាតៈ គឺពួកវិបាកធម្មធម្មក្ខន្ធក្តី ពួកមហាភូតក្តី (ជាបច្ច័យ) នៃពួកចិត្តសមុដ្ឋានរូប។ ឯបច្ឆាជាតៈ

គឺពួកវិបាកធម្មធម្មក្ខន្ធក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ។ ឯបច្ឆាជាតៈ គឺពួកវិបាកធម្មធម្មក្ខន្ធក្តី រូបជីវិតិន្ទ្រិយក្តី (ជាបច្ច័យ) នៃពួកកដត្តារូប។ វិបាកធម៌ គឺនត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ប្រហែលគ្នានឹងអនន្តរប្បច្ច័យ អវិគតប្បច្ច័យ ប្រហែលគ្នានឹងអត្ថិប្បច្ច័យ។

[១៦៨] ក្នុងហេតុប្បច្ច័យ មានវារៈ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ១០ ក្នុងអនន្តរប្បច្ច័យ មានវារៈ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ១១ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៧ ក្នុងនិស្សយប្បច្ច័យ មានវារៈ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ២ ក្នុងកម្មប្បច្ច័យ មានវារៈ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ៣ ក្នុងអាហារប្បច្ច័យ មានវារៈ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៩ ក្នុងឈានប្បច្ច័យ មានវារៈ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ៧ ក្នុងវិគតប្បច្ច័យ មានវារៈ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ១៣។

[១៦៩] ក្នុងអធិបតិប្បច្ច័យ មានវារៈ៧ ព្រោះហេតុប្បច្ច័យ ... ក្នុងសហជាតប្បច្ច័យ មានវារៈ៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងវិប្បយត្តប្បច្ច័យ មានវារៈ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ៧។

ការរាប់ជាអនុលោម នូវបញ្ហាវារៈក្នុងកុសលត្តិកៈ ដែលលោកបានរាប់ហើយយ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ។

ចប់ អនុលោម។

[១៧០] វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យ ដោយសហជាតប្បច្ច័យ ... ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ វិបាកធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យ ដោយសហជាតប្បច្ច័យ ... ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ។ វិបាកធម៌ ជាបច្ច័យនៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយសហជាតប្បច្ច័យ។

[១៧១] វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យ ដោយសហជាតប្បច្ច័យ ... ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យដោយកម្មប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យ ដោយសហជាតប្បច្ច័យ ... ជាបច្ច័យ ដោយឧបនិស្សយបច្ច័យ ... ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ... ជាបច្ច័យ ដោយកម្មប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យ នៃវិបាកធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយកម្មប្បច្ច័យ។ វិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ផង នៃនេវវិបាកនវិបាកធម្មធម៌ផង ដោយសហជាតប្បច្ច័យ។

[១៧២] នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យ នៃនេវវិបាកនវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យ ដោយសហជាតប្បច្ច័យ ... ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ... ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ... ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យ ដោយសហជាតប្បច្ច័យ ... ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ... ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។ នេវវិបាកនវិបាកធម្មធម៌ ជាបច្ច័យនៃវិបាកធម្មធម៌ ដោយអារម្មណប្បច្ច័យ ... ជាបច្ច័យ ដោយឧបនិស្សយបច្ច័យ ... ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ។

[១៧៣] វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី (ជាបច្ច័យ) នៃវិបាកធម៌ បានដល់សហជាតៈ និងបុរេជាតៈ។ វិបាកធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី (ជាបច្ច័យ) នៃនេវវិបាកនវិបាកធម្មធម៌ បានដល់សហជាតៈ បច្ឆាជាតៈ អាហារ និងឥន្ទ្រិយ។

[១៧៤] វិបាកធម្មធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី (ជាបច្ច័យ) នៃវិបាកធម្មធម៌ បានដល់សហជាតៈ និងបុរេជាតៈ។ វិបាកធម្មធម៌ក្តី នេវវិបាកនវិបាកធម្មធម៌ក្តី (ជាបច្ច័យ) នៃនេវវិបាកនវិបាកធម្មធម៌ បានដល់សហជាតៈ បច្ឆាជាតៈ អាហារ និងឥន្ទ្រិយ។

[១៧៥] ក្នុងនហេតុប្បច្ច័យ មានវារៈ១៦ ក្នុងនអារម្មណប្បច្ច័យ មានវារៈ១៦ ក្នុងនអធិបតិប្បច្ច័យ មានវារៈ១៦ ក្នុងនអនន្តរប្បច្ច័យ មានវារៈ១៦ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ១៦ ក្នុងនសហជាតប្បច្ច័យ មានវារៈ១២ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ១២ ក្នុងននិស្សយប្បច្ច័យ មានវារៈ១២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ១៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ១៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ១៦ ក្នុងនអាសេវនប្បច្ច័យ មានវារៈ១៦ ក្នុងនកម្មប្បច្ច័យ មានវារៈ១៥ ក្នុងនវិបាកប្បច្ច័យ មានវារៈ១៤ ក្នុងនអាហារប្បច្ច័យ មានវារៈ១៦ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ១៦ ក្នុងនឈានប្បច្ច័យ មានវារៈ១៦ ក្នុងនមគ្គប្បច្ច័យ មានវារៈ១៦ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ១២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ១០ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ១០ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ១៦ ក្នុងនោវិគតប្បច្ច័យ មានវារៈ១៦ ក្នុងនោអវិគតប្បច្ច័យ មានវារៈ១០។

[១៧៦] ក្នុងនអារម្មណប្បច្ច័យ មានវារៈ១៦ ព្រោះនហេតុប្បច្ច័យ។ សេចក្តីបំប្រួញ ... ក្នុងនោវិគតប្បច្ច័យ មានវារៈ១០។ ដែលបណ្ឌិតគប្បីឲ្យពិស្តារ ដូចជាការរាប់នូវបច្ចនីយៈ ក្នុងកុសលត្តិកៈ ដែលលោកឲ្យពិស្តារហើយដែរ។

ចប់ បច្ចនីយៈ។

[១៧៧] ក្នុងនអារម្មណប្បច្ច័យ មានវារៈ៧ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ៧ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ៧ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ៣ ក្នុងនឧបនិស្សយបច្ច័យ មានវារៈ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ៧ ក្នុងនកម្មប្បច្ច័យ មានវារៈ៧ ក្នុងនវិបាកប្បច្ច័យ មានវារៈ៤ ក្នុងនអាហារប្បច្ច័យ មានវារៈ៧ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ៧ ក្នុងនឈានប្បច្ច័យ មានវារៈ៧ ក្នុងនមគ្គប្បច្ច័យ មានវារៈ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ៧។

[១៧៨] ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដូច្នេះ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៧ ព្រោះហេតុប្បច្ច័យ។ សេចក្តីបំប្រួញ។ ... ក្នុងនោវិគតប្បច្ច័យ មានវារៈ៧។ បណ្ឌិត គប្បីឲ្យពិស្តារ ដូចជាការរាប់នូវអនុលោមបច្ចនីយៈ ក្នុងកុសលត្តិកៈ ដែលលោកឲ្យពិស្តារហើយដែរ។ នេះជាផ្លូវនៃការស្វាធ្យាយ ដែលបុគ្គលអ្នកមិនវង្វេង (គប្បីឲ្យពិស្តារចុះ)។

ចប់ អនុលោមបច្ចនីយៈ។

[១៧៩] ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ១០ ក្នុងអនន្តរប្បច្ច័យ មានវារៈ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ១១ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៧ ក្នុងនិស្សយប្បច្ច័យ មានវារៈ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ២ ក្នុងកម្មប្បច្ច័យ មានវារៈ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ៣ ក្នុងអាហារប្បច្ច័យ មានវារៈ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ៩ ក្នុងឈានប្បច្ច័យ មានវារៈ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ៥

ក្នុងអត្ថិប្បច្ច័យ មានវារៈ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ៧ ក្នុងវិគតប្បច្ច័យ មានវារៈ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ១៣។

[១៨០] ក្នុងអធិបតិប្បច្ច័យ មានវារៈ៧ ព្រោះនហេតុប្បច្ច័យ ព្រោះនអារម្មណប្បច្ច័យ។ សេចក្ដីបំប្រួញ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ១៣។ បណ្ឌិត គប្បីឲ្យពិស្ដារ ដូចជាការរាប់នូវបច្ចនីយានុលោម ក្នុងកុសលត្តិកៈ ដែលលោកឲ្យពិស្ដារហើយដែរ។

ចប់ បច្ចនីយានុលោម។

ចប់ វិបាកត្តិកៈ ទី៣។

## ឧបាទិន្នត្តិកៈ

### បដិច្ចវារៈ

